

# ជំនាញសម្របសម្រួល

សម្របសម្រួលដោយៈ គោល សិលា

# គោលបំណង

នៅចុងបញ្ចប់នៃមេរៀន ដែលមានរយៈពេល៣០នាទី អ្នកចូលរួមទាំងអស់នឹងអាចទទួលបាន៖

- ➢ អាចកំណត់បានអំពីការសម្របសម្រួល និង
- ➢ សម្របសម្រួលកិច្ចប្រជុំសហគមន៍ឱ្យកាន់តែមានប្រសិទ្ធិភាព

# មាតិកា

- និយមន័យ
- អាកប្បកិរិយា និងកាយវិការរបស់អ្នកសម្របសម្រួល
- ប្រការអ្នកសម្របសម្រួលត្រូវជៀសវាង

# តើការសម្របសម្រួលជាអ្វី ?

**ការសម្របសម្រួល** គឺជាការធ្វើឱ្យកិច្ចការមួយមានដំណើរការងាយស្រួល និងសម្រេចតាមគោលបំណង ដែលបានគ្រោងទុក។ ជាពិសេសវាធ្វើឱ្យកាន់តែមានភាពប្រសើរឡើងក្នុងការចូលរួមពិភាក្សា ដោះស្រាយបញ្ហា និងការរៀនសូត្រ និងដោះស្រាយបញ្ហាជាមួយគ្នា។



# អាកប្បកិរិយា និងកាយវិការរបស់អ្នកសម្របសម្រួល

១

## អាកប្បកិរិយាដែលត្រូវធ្វើ

### ក. ពាក្យសម្ដី

- និយាយច្បាស់ៗ និងបែរមុខទៅរកសិក្ខាកាម
- បញ្ជាក់អំពីគោលបំណងរបស់កម្មវិធីឱ្យបានច្បាស់
- យល់ពីអារម្មណ៍ និងការការរំពឹងទុករបស់សិក្ខាកាម
- ប្រើពាក្យពេចន៍សាមញ្ញដែលសិក្ខាកាមងាយយល់
- លើកទឹកចិត្ត និងផ្ដល់ឱកាសសិក្ខាកាមក្នុងការសួរសំណួរ
- បង្កើត ឬបំផុសសំណួរឱ្យមានលក្ខណៈច្បាស់លាស់



១

# អាកប្បកិរិយាដែលត្រូវធ្វើ (បន្ត)

## ខ. ទឹកមុខ

- ប្រើទឹកមុខញញឹមទៅកាន់សិក្ខាកាម
- ប្រើនូវអារម្មណ៍របស់ខ្លួនមួយចំនួនដូចជា ការភ្ញាក់ផ្អើល ព្រួយបារម្មណ៍ ឬសប្បាយរីករាយជាដើម
- ប្រើការអង្កេតទឹកមុខរបស់សិក្ខាកាម តែមិនត្រូវផ្តោតអារម្មណ៍លើរឿងរបស់សិក្ខាកាមច្រើនពេក នាំឱ្យបែកអារម្មណ៍។

១

# អាកប្បកិរិយាដែលត្រូវធ្វើ (បន្ត)

## គ. ភ្នែក

- សម្លឹងមើលសិក្ខាកាមឱ្យបានគ្រប់គ្នា (មើល មុខ ឆ្វេង ស្តាំ)
- ជៀសវាងការសម្លឹងមើលសិក្ខាកាមមិនដាក់ភ្នែក



១

## អាកប្បកិរិយាដែលត្រូវធ្វើ (បន្ត)

### ឃ. សម្លេង

- និយាយឱ្យបានលឺច្បាស់លាស់ ខ្លីតែខ្លឹម
- ជៀសវាងការនិយាយពាក្យ "អឺ អឺ អឺ" ច្រើនដង
- ប្រើការលើកដាក់សម្លេង ប្រកបដោយការជឿជាក់
- ត្រូវសង្កត់ធ្ងន់លើពាក្យគន្លឹះ ឬចំណុចដែលមានសារៈសំខាន់ឱ្យសិក្ខាកាមចាប់អារម្មណ៍

២

# កាយវិការដែលត្រូវធ្វើ

- ត្រូវមានកាយវិការសមរម្យ (ចៀសវាងការប្រើម្រាមដៃមួយចង្អុលទៅសិក្ខាកាម ឬលើកដៃច្រងេងច្រងាង)
- ត្រូវដើរចុះឡើង តែមិនញឹកញាប់ពេកទេ
- ឈរឱ្យបានសមរម្យនៅត្រង់កន្លែងដែលមិនរំខាន ឬប៉ះពាល់ដល់ចំណាប់អារម្មណ៍របស់សិក្ខាកាម
- ការធ្វើចលនានានាត្រូវមានគោលបំណងច្បាស់លាស់


Network:19 Oct 2021 at 8:37:41 AM GMT+7
Local:19 Oct 2021 at 8:37:41 AM GMT+7
USAID

៣

## ការប្រាស្រ័យទាក់ទង

- ត្រូវមានការទាក់ទងតាមបែបពហុទិស (មិនមែនសួរមកសិក្ខាកាម ប៉ុន្តែបែរមុខទៅទិសផ្សេងទេ)
- ផ្តល់ឱកាសដល់សិក្ខាកាមចែករំលែក និងសួរសំណួរឱ្យបានច្រើន (ជៀសវាងការនិយាយច្រើនជាងសិក្ខាកាម)
- ជៀសវាងការនិយាយប្រណាំងប្រជែងជាមួយសិក្ខាកាម
- ពេលមានសិក្ខាកាមណាមួយសួរសំណួរ ត្រូវទុកឱកាសឱ្យសិក្ខាកាមដទៃទៀតឡើងពន្យល់សាកល្បង។

៤

## សម្លៀកបំពាក់

- ស្លៀកសម្លៀកបំពាក់ណា ដែលមិនតឹងពេក ឬធូររលុងពេក
- ត្រួតពិនិត្យមើលឡេវ ខ្សែរូតខោ-សំពត់
- ពិនិត្យមើលសក់ និងរបៀបរៀបរយនានាឱ្យបានត្រឹមត្រូវ
- ជៀសវាងការស្លៀកសម្លៀកបំពាក់ ដែលមានពណ៌ស្រស់ឆើតឆាយពេក។

# ប្រការអ្នកសម្របសម្រួលត្រូវចៀសវាង

- មិនត្រូវបន្ទោស ឬបង្គាប់សិក្ខាកាមឱ្យធ្វើអ្វីមួយ
- មិនត្រូវធ្វើអាកប្បកិរិយាមិនគប្បី
- អ្វីដែលមិនច្បាស់លាស់មិនត្រូវលើកមកនិយាយ
- មិនត្រូវឆ្លើយសំណួរដោយខ្លួនឯង ត្រូវរង់ចាំចម្លើយពីសិក្ខាកាម
- មិនត្រូវបដិសេដមតិយោបល់ ឬបំបាក់ទឹកចិត្តសិក្ខាកាម
- កុំនិយាយតែម្នាក់ឯងច្រើនពេក

# អរគុណ!

ប្រសិនបើមានសំណួរបន្ថែម បងប្អូនអាចទំនាក់ទំនង៖

តេលេក្រាម៖ 016 718 486

សារអេឡិចត្រូនិច៖ ksela@psi.org.kh